ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តសៀមរាប

-សាលក្រមរដ្ឋប្បវេណីលេខ: ៣១ "ម"/២៧១
ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២
-សំណុំរឿងរដ្ឋប្បវេណីលេខ: ២៧០
ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

-បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ រសៀល។

-បានប្រកាសសាលក្រម នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ ព្រឹក នៅសវនាការ នៃសាលាដំបូងខេត្តសៀមរាប។

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

លើសំណុំរឿងរដ្ឋប្បវេណីលេខ ២៧០ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដែលមាន៖

-**ដើមចោទ**ឈ្មោះ [redacted] សុភា ភេទស្រី កើតឆ្នាំ១៩៨៨ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។

មានលោកស្រី [redacted] និងលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-**ចុងចម្លើយ**ឈ្មោះ [redacted] ចាន់រ៉ា ភេទប្រុស កើតឆ្នាំ១៩៨៤ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។



Scanned with CamScanner

## អង្គហេតុ និងចំណុចវិវាទ

### I- ការទាមទាររបស់ដើមចោទ

ដើមចោទបានប្ដឹងសុំទាមទារឲ្យតុលាការចេញសាលក្រម ដូចខាងក្រោម:

១.ឲ្យដើមចោទឈ្មោះ [redacted] សុភា លែងលះពីចុងចម្លើយឈ្មោះ [redacted] ចាន់រ៉ា ដែលមានសំបុត្រអាពាហ៍ពិពាហ៍ លេខ ៤១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] ចាន់រ៉ា និងឈ្មោះ [redacted] សុភា។

២.ឲ្យដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើកូនៈ

ក.ឈ្មោះ [redacted] សារ៉ាភារ័ត្តិ ភេទស្រី កើតថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៤ ដែលមានសំបុត្រកំណើត លេខ ១៥០ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤។

ខ.ឈ្មោះ [redacted] ស៊ូស៊ូ ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ដែលមានសំបុត្របញ្ជាក់កំណើត លេខ ៩៣៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨។

៣.បែងចែកទ្រព្យសម្បត្តិរួមមានៈ

ក.ដីមួយកន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០២០២-១០៣២ លេខក្បាលដី ១០៣២ ទំហំ ៨៩៨ ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ត្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាពីរចំណែកស្មើគ្នា។

ខ.ដីមួយកន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០២-០១៩៤ លេខក្បាលដី ១៩៤ ទំហំ ៧២៤ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ត្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ប្រគល់ឲ្យដើមចោទ ព្រោះដីនេះជាឈ្មោះរបស់ឪពុកម្ដាយដើមចោទ ដើម្បីកុំឲ្យពិបាកក្នុងការផ្ទេរសិទ្ធិ។

គ.ឡានមួយគ្រឿង ម៉ាក LEXUS 300 ពណ៌ប្រាក់ ស្លាកលេខ ភ្នំពេញ ២N-៥១៤១ ប្រគល់ឲ្យទៅចុងចម្លើយ។

៤.ឲ្យចុងចម្លើយបង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុង ០១ (មួយ) ខែ ចំនួន ២៥០ (ពីររយហាសិប) ដុល្លារអាមេរិក។

៥.ឲ្យដើមចោទជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដីតុលាការ។



Scanned with CamScanner

**II-ការសង្ខេបអំពីរឿងក្តី**

ដើមចោទឈ្មោះ [redacted] សុភា ភេទស្រី និងចុងចម្លើយឈ្មោះ [redacted] ចាន់រ៉ា ភេទប្រុស បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដូចមានបញ្ជាក់ក្នុងសំបុត្រអាពាហ៍ពិពាហ៍ លេខ ៤១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ស្វាយដង្គំ។ ក្នុងចំណងអាពាហ៍ពិពាហ៍ដើមចោទ និងចុងចម្លើយមានកូនពីរនាក់ឈ្មោះ [redacted] សារ៉ាភាវត្តី ភេទស្រី កើតថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៤ និងឈ្មោះ [redacted] ស៊ូស៊ូ ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ និងទ្រព្យសម្បត្តិរួមមួយចំនួន។ ដោយសាររស់នៅមិនចុះសម្រុងនឹងគ្នា ទើបដើមចោទបានសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះ ប៉ុន្តែចុងចម្លើយបានបដិសេធមិនព្រមលែងលះ។

**III-សេចក្តីថ្លែងការណ៍របស់គូភាគី**

ឈ្មោះ [redacted] សុភា ជាដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួននៅតែសុំ**១**.ឲ្យតុលាការសម្រេចឲ្យខ្លួនបានលែងលះពីចុងចម្លើយឈ្មោះ មាន ចាន់រ៉ា ដែលមានសំបុត្រអាពាហ៍ពិពាហ៍ លេខ ៤១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ មូលហេតុដែលខ្លួនចង់លែងលះ គឺដោយសារចុងចម្លើយតែងផឹកស៊ី រករឿងខ្លួន វាយដំខ្លួន ជេរប្រមាថឪពុកម្តាយខ្លួន ជាញឹកញាប់ដែលធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធ រងការឈឺចាប់មិនអាចទ្រាំទ្របានទៀត ទើបខ្លួនសម្រេចចិត្តដាក់ពាក្យបណ្តឹងលែងលះ។ ម្យ៉ាងខ្លួនចាប់បានគាត់ឆាតជាមួយស្រី បបួលគ្នាដេកជាមួយគ្នា ទៀត ទើបខ្លួនមិនអាចទ្រាំបាន។ **២**.សុំសិទ្ធិមានអំណាចមេបាលើកូន ឈ្មោះ [redacted] សារ៉ាភាវត្តី ភេទស្រី កើតថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៤ និងឈ្មោះ [redacted] ស៊ូស៊ូ ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦, **៣**.សុំបែងចែកទ្រព្យសម្បត្តិរួមមាន ដីមួយកន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០២០២-១០៣២ លេខក្បាលដី ១០៣២ ទំហំ ៨៩៨ ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ទ្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាពីរចំណែកស្មើគ្នា និងដីមួយកន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០២-០១៩៤ លេខក្បាលដី ១៩៤ ទំហំ ៧២៤ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ទ្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដីនេះឈ្មោះកម្មសិទ្ធិករ គឺឪពុកម្តាយខ្លួន ព្រោះខ្លួន និងចុងចម្លើយទិញរួមគ្នា ពីម្តាយឪពុកខ្លួន ប៉ុន្តែមិនទាន់បានកាត់ឈ្មោះទេ គឺខ្លួនយល់ព្រមបែងចែកជាពីរចំណែកស្មើគ្នា, **៤**. ឡានមួយគ្រឿង ម៉ាក LEXUS 300 ពណ៌ប្រាក់ ស្លាកលេខ ភ្នំពេញ ២N-៥១៤១ សុំបែងចែកជាពីរចំណែកស្មើគ្នា, **៥**.ចំពោះប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមសុំឱ្យចុងចម្លើយបង់តាមលទ្ធភាពវិញ និង**៦**.ប្រាក់ប្រដាប់ក្តីតុលាការខ្លួនជាអ្នកទទួលបន្ទុក។

ចំពោះទ្រព្យសម្បត្តិមួយចំនួន ដែលចុងចម្លើយសុំបន្ថែមនោះ គឺម៉ូតូពីរគ្រឿង មួយគ្រឿង ម៉ាក ឃ្លីច ពណ៌ស ផ្លាកលេខ សៀមរាប ១AD-១១៤៩ និងមួយគ្រឿងទៀតម៉ាក ឌ្រីម សេរីឆ្នាំ២០១៦ ពណ៌ខ្មៅ ផ្លាកលេខ សៀមរាប ១V-៧៧៤១ ខ្លួនយល់ព្រមបែងចែកជាពីរចំណែកស្មើគ្នា ដោយខ្លួនសុំម៉ូតូ ម៉ាក ឌ្រីម សេរីឆ្នាំ២០១៦ ពណ៌ខ្មៅ ផ្លាកលេខ សៀមរាប ១V-៧៧៤១ ចំណែកម៉ូតូមួយគ្រឿងទៀត ម៉ាក ឃ្លីច ពណ៌ស ផ្លាកលេខ សៀមរាប ១AD-១១៤៩ ប្រគល់ឲ្យចុងចម្លើយ។ កង់ហាត់ប្រាណ មួយ ព្រម ប្រគល់ឲ្យចុងចម្លើយ។ ឥវ៉ាន់គ្រឿងកសិកម្ម ដែលកំពុងលក់រាល់ថ្ងៃ ខ្លួនមិនអាចបែងចែកបានទេ ដោយ សារឥវ៉ាន់ទាំងនោះ គឺក្រុមហ៊ុនលក់ផលិតកសិកម្មនោះ ពួកគាត់ដាក់ឥវ៉ាន់ឲ្យខ្លួនលក់មុន ទើបខ្លួនបង្វិល ប្រាក់ឲ្យតាមក្រោយ ទើបមិនអាចបែងចែកបានទេ។ ចំពោះគ្រឿងអលង្ការ មានខ្សែកពីរខ្សែ មួយខ្សែលក់ បង់សាលាកូនបាត់ហើយ មួយខ្សែទៀត នៅនឹងខ្លួន មិនព្រមចែកទេ ព្រោះមានចញ្ចៀនមួយវង់ទៀត នៅ នឹងចុងចម្លើយ គឺខ្លួនព្រមប្រគល់ឲ្យគាត់ មិនទាមទារនោះទេ។ មានកៅអីតុក្កតា ចំនួន ៨គ្រាប់ សុំបែងចែក ជាពីរចំណែកស្មើគ្នា។

កូនរាល់ថ្ងៃនៅជាមួយខ្លួនទាំងពីរនាក់ អាយុ៨ឆ្នាំម្នាក់ និង៦ឆ្នាំម្នាក់។ រាល់ថ្ងៃប្ដីខ្លួនគាត់នៅ តូបលក់គ្រឿងកសិកម្មរាល់ថ្ងៃ ពេលថ្ងៃខ្លួនទៅលក់ធម្មតា ពេលយប់ខ្លួនទៅដេកផ្ទះម្ដាយខ្លួន។ ដីមួយ កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០២-០១៩៤ លេខក្បាលដី ១៩៤ ទំហំ ៧២៤ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ត្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្ត សៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាទ្រព្យសម្បត្តិរួម ទិញពីឪពុកម្ដាយខ្លួន មិនទាន់បានផ្ទេរសិទ្ធិ ទេ តម្លៃ ៣.៥០០ដុល្លារអាមេរិក ព្រមបែងចែកជាពីរស្មើគ្នាដដែល។

ឈ្មោះ [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ ថា កូនក្ដីខ្លួននៅតែមិនព្រមលែងលះដដែល ដោយបញ្ជាក់ថា នៅស្រលាញ់ប្រពន្ធកូន។ តែបើតុលាការ សម្រេចឲ្យលែងលះ កូនក្ដីខ្លួនសុំសិទ្ធិមានអំណាចមេបាលើកូនម្នាក់ឈ្មោះ [redacted] សារ៉ាភាវត្តី។ ទ្រព្យសម្បត្តិ រួមមាន ដីមួយកន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០២០២-១០៣២ លេខក្បាលដី ១០៣២ ទំហំ ៨៩៨ ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ត្រក សង្កាត់ស្វាយដង្គំ ក្រុង សៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ និងដីមួយកន្លែង ដែលមានវិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០២-០១៩៤ លេខក្បាលដី ១៩៤ ទំហំ ៧២៤ម៉ែត្រការេ មាន អាសយដ្ឋានស្ថិតនៅ ភូមិកន្ត្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៦ និងឡានមួយគ្រឿង ម៉ាក LEXUS 300 ពណ៌ប្រាក់ ស្លាកលេខ ភ្នំពេញ ២N-៥១៤១ យល់ព្រម

បែងចែកជាពីរចំណែកស្មើគ្នា, ចំពោះប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនព្រមបង់តាមលទ្ធភាពតាមការទាមទារ, ប្រាក់ប្រដាប់ក្តីតុលាការយល់ព្រមឱ្យដើមចោទជាអ្នកទទួលបន្ទុក។

ចំពោះទ្រព្យសម្បត្តិមួយចំនួន មាន គឺម៉ូតូពីរគ្រឿង មួយគ្រឿងម៉ាក ឃ្លីច ពណ៌ស ផ្លាកលេខ សៀមរាប ១AD-១១៤៩ និងមួយគ្រឿងទៀតម៉ាក ឌ្រីម សេរីឆ្នាំ២០១៦ ពណ៌ខ្មៅ ផ្លាកលេខ សៀមរាប ១V-៧៧៤១ កូនក្តីខ្លួនយល់ព្រមបែងចែកជាពីរចំណែកស្មើគ្នា ដោយព្រមប្រគល់ម៉ូតូម៉ាក ឌ្រីម សេរីឆ្នាំ២០១៦ ពណ៌ខ្មៅ ផ្លាកលេខ សៀមរាប ១V-៧៧៤១ ឲ្យទៅដើមចោទ ចំណែកម៉ូតូមួយគ្រឿងទៀត ម៉ាក ឃ្លីច ពណ៌ស ផ្លាកលេខ សៀមរាប ១AD-១១៤៩ ប្រគល់ឲ្យកូនក្តីខ្លួន គាត់ព្រមទទួលយក។ កង់ហាត់ប្រាណមួយ កូនក្តីខ្លួនព្រមទទួលយក។

ចំពោះគរ៉ាន់គ្រឿងកសិកម្ម ដែលកំពុងលក់រាល់ថ្ងៃ កូនក្តីខ្លួននៅតែស្នើសុំបែងចែកជាពីរចំណែកស្មើគ្នា។ ចំពោះគ្រឿងអលង្ការ មានខ្សែកពីរខ្សែ មួយខ្សែដើមចោទលក់បង់សាលាកូនបាត់ហើយ មួយខ្សែទៀត នៅនឹងដើមចោទ កូនក្តីខ្លួនព្រមប្រគល់ឲ្យដើមចោទ ហើយចញ្ចៀនមួយវង់ទៀត នៅនឹងកូនក្តីខ្លួន គឺគាត់ព្រមទទួលយក។ ចំពោះកៅអីតុក្កតា ចំនួន ៨គ្រាប់ កូនក្តីខ្លួនយល់ព្រមបែងចែកជាពីរចំណែកស្មើគ្នា។ ក្រៅពីនេះ មិនមានទ្រព្យសម្បត្តិរួមផ្សេងទៀតទេ។

ខ្លួនសុំធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ថា ចំណុចទី១ មូលហេតុនៃការលែងលះ តាមក្រមនីតិវិធីរដ្ឋប្បវេណី គឺមិនស្របតាមមាត្រា ៩៧៨ នោះទេ ដោយមានចែងលក្ខណគ្រប់គ្រាន់ ដោយកូនក្តីខ្លួនមិនបានប្រព្រឹត្តដូចមូលហេតុនៃការលែងលះនោះទេ។ ទាក់ទងនឹងដីដែលជាទ្រព្យសម្បត្តិរួមរបស់ពួកគាត់ តាមមាត្រា ៩៧៣ នៃក្រមនីតិវិធិរដ្ឋប្បវេណី ឃើញថា ទ្រព្យនេះ ជាទ្រព្យរួមប្តីប្រពន្ធពិតមែន ទោះបីជាមានទ្រព្យមួយមិនទាន់បានផ្ទេរសិទ្ធិក៏ដោយ ក៏អាចត្រូវធ្វើការបែងចែកដែរ។ ចំណែកគ្រឿងកសិកម្ម ទោះបីជាប់បំណុលក៏ដោយ ជាទ្រព្យដែលតុលាការអាចធ្វើការបែកចែកដែរ។ ចំពោះកូន គឺកូនក្តីខ្លួននៅតែទាមទារដដែល។

**VI-អង្គហេតុដែលគ្មានវិវាទ ៖** គ្មាន។

**V-អង្គហេតុដែលមានវិវាទ ៖**

១.តើដើមចោទមានមូលហេតុនៃការលែងលះ ត្រឹមត្រូវ ឬទេ។

២.តើដីមួយកន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០២-០១៩៤ លេខក្បាលដី ១៩៤ ទំហំ ៧២៤ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ត្រក សង្កាត់ស្វាយដង្គំ ក្រុង



Scanned with CamScanner

សៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ និងគ្រឿងកសិកម្ម គូភាគីអាចទាមទារឱ្យតុលាការធ្វើការបែងចែកបាន ឬទេ។

**ការពិនិត្យភស្តុតាង**

**I-ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.សំបុត្រអាពាហ៍ពិពាហ៍ លេខ ៤១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ស្វាយដង្គំ។

២.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០២០២-១០៣២ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦។

៣.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០២០២-០១៩៤ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦។

៤.សំបុត្រកំណើត លេខ ១៥០ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤។

៥.សំបុត្របញ្ជាក់កំណើត លេខ ៩៣៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨។

៦.ពាក្យស្នើសុំបញ្ចូលភស្តុតាង ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២។

៧.ឯកសារផ្សេងៗ។

**II-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ គ្មាន។**

**សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរ និងការពិនិត្យភស្តុតាងនានា ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តុលាការ **យល់ឃើញថា៖**

**១**-តាមពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សុភា គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ស្របតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បី តុលាការយកមកពិនិត្យ និងសម្រេចតាមច្បាប់បាន។

**២**-តាមសំបុត្រអាពាហ៍ពិពាហ៍ លេខ ៤១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ស្វាយដង្គំ បញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] សុភា និងចុងចម្លើយឈ្មោះ [redacted] ចាន់រ៉ាពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវស្របតាមច្បាប់ ប្រាកដមែន គប្បី តុលាការអាចលើកយកមកពិនិត្យ និងសម្រេចតាមការទាមទាររបស់ដើមចោទ បាន។



Scanned with CamScanner

**៣**-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ បានបញ្ជាក់ថា ខ្លួនសុំលែងលះពីចុងចម្លើយ ឈ្មោះ [redacted] ចាន់រ៉ា ដោយសារចុងចម្លើយតែងផឹកស៊ី រករឿងខ្លួន វាយដំខ្លួន ជេរប្រមាថឪពុកម្តាយខ្លួន ជាញឹកញាប់ដែលធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធ រងការឈឺចាប់មិនអាចទ្រាំទ្របានទៀត និងធ្លាប់ចាប់បានគាត់ឆាតជាមួយស្រី បបួលគ្នាដេកជាមួយគ្នាទៀត ទើបខ្លួនមិនអាចទ្រាំបាន ហើយចុងចម្លើយក៏បានទទួលស្គាល់ដែរថា ខ្លួនពិតជាបានប្រព្រឹត្តដូចការលើកឡើងរបស់ដើមចោទ ប្រាកដមែន តុលាការយល់ឃើញថា អាពាហ៍ពិពាហ៍នេះ ត្រូវបានបែកបាក់ ដោយមិនអាចធ្វើបដិទានបាន ដោយដើមចោទបានបញ្ជាក់អំពីមូលហេតុនៃការលែងលះគ្នា ដែលតុលាការអាចពិនិត្យ និងសម្រេចបាន ផ្អែកតាមបញ្ញត្តិ ៩៧៨ នៃក្រមរដ្ឋប្បវេណី។

**៤**-ចំពោះដីមួយកន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០២០២-១០៣២ លេខក្បាលដី ១០៣២ ទំហំ ៨៩៨ ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ទ្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ គឺជាកម្មសិទ្ធិរបស់ដើមចោទ និងចុងចម្លើយ ប្រាកដមែន តុលាការនឹងសម្រេចបែងចែង តាមការព្រមព្រៀង ចំណែកដីមួយកន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០២-០១៩៤ លេខក្បាលដី ១៩៤ ទំហំ ៧២៤ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ទ្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ មិនមែនជាកម្មសិទ្ធិរបស់ដើមចោទ និងចុងចម្លើយ នោះទេ ដូច្នេះ តុលាការនឹងមិនសម្រេចបែងចែង តាមការព្រមព្រៀងនោះទេ។

**៥**-ចំពោះទ្រព្យរួមសម្បត្តិមាន គឺម៉ូតូពីរគ្រឿង មួយគ្រឿងម៉ាក ឃ្លីច ពណ៌ស ផ្លាកលេខ សៀមរាប ១AD-១១៤៩, មួយគ្រឿងម៉ាក ឌ្រីម សេរីឆ្នាំ២០១៦ ពណ៌ខ្មៅ ផ្លាកលេខ សៀមរាប ១V-៧៧៤១, គ្រឿងអលង្ការ ខ្សែក, ចញ្ចៀន, កៅអីតុក្កតា ចំនួន ៨គ្រាប់ និងឡានមួយគ្រឿង ម៉ាក LEXUS 300 ពណ៌ប្រាក់ ស្លាកលេខ ភ្នំពេញ ២N-៥១៤១ ដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នាលើការបែងចែក និងបានកាន់កាប់ជាក់ស្តែងរៀងៗខ្លួន រួចរាល់ហើយ ដូច្នេះ តុលាការមិនលើកយកចំណុចនេះ មកសម្រេចនោះទេ។

**៦**-ចំពោះគ្រឿងកសិកម្ម ដែលចុងចម្លើយទាមទារឲ្យតុលាការធ្វើការបែងចែងនោះ តុលាការនឹងមិនសម្រេចធ្វើការបែងចែកនោះទេ ព្រោះមិនមែនជាទ្រព្យសម្បត្តិរួម និងបំណុលរួមរបស់ដើមចោទ និងចុងចម្លើយដែលត្រូវធ្វើការបែងចែកបាននោះទេ ដោយសារគ្រឿងកសិកម្មនោះជារបស់ក្រុមហ៊ុន ដែលគេដាក់ឲ្យដើមចោទជួយលក់ និងបង្វិលប្រាក់ឲ្យក្រុមហ៊ុនវិញពេលលក់បានតាមក្រោយ។



Scanned with CamScanner

៧-ដើមចោទឈ្មោះ [redacted] សុភា និងចុងចម្លើយឈ្មោះ មាន ចាន់រ៉ា មិនបានព្រមព្រៀងគ្នាអំពីអ្នកមានសិទ្ធិមានអំណាចមេបាគ្រប់គ្រងលើកូននោះទេ ដោយដើមចោទទាមទារសិទ្ធិមានអំណាចមេបាគ្រប់គ្រងលើកូនឈ្មោះ [redacted] សារ៉ាភាវត្តី ភេទស្រី កើតថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៤ និងឈ្មោះ [redacted] ស៊ូស៊ូ ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ចំណែកចុងចម្លើយទាមទារសិទ្ធិមានអំណាចមេបាគ្រប់គ្រងលើកូនឈ្មោះ [redacted] សារ៉ាភាវត្តី ភេទស្រី កើតថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៤ តុលាការយល់ឃើញថា ដោយសារបច្ចុប្បន្នកូនទាំងពីរ ខាងលើ កំពុងតែរស់នៅ និងស្ថិតក្រោមការគ្រប់គ្រងរបស់ដើមចោទ ហើយដើមចោទជាស្ត្រីអាចមើលថែទាំកូនបានល្អជាង តាមបញ្ញត្តិមាត្រា ១០៣៧ ចំណុច៣ នៃក្រមរដ្ឋប្បវេណី បើឪពុកម្ដាយពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើប្រយោជន៍របស់កូននោះ ដូច្នេះ តុលាការនឹងសម្រេចប្រគល់សិទ្ធិមានអំណាចមេបាគ្រប់គ្រងលើកូនឲ្យទៅដើមចោទ ហើយភាគីម្ខាងទៀតជាឪពុកដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីជាម្ដាយដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត យោងតាមបញ្ញត្តិមាត្រា ១០៤០ និងមាត្រា ១០៤១ នៃក្រមរដ្ឋប្បវេណី។

៨-ចំពោះប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូន ឲ្យចុងចម្លើយបង់តាមលទ្ធភាពរហូតកូនដល់នីតិភាព តាមការព្រមព្រៀងរបស់គូភាគី។

៩-ប្រាក់ប្រដាប់ក្ដី តុលាការនឹងសម្រេចជាបន្ទុករបស់ភាគីដើមចោទ តាមការព្រមព្រៀងរបស់គូភាគី។

## សេចក្ដីសម្រេចបញ្ចប់

**១-ឱ្យ**ដើមចោទឈ្មោះ [redacted] សុភា លែងលះពីចុងចម្លើយឈ្មោះ [redacted] ចាន់រ៉ា។

**២-ឱ្យ**ដើមចោទឈ្មោះ [redacted] សុភា ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ១២០ (មួយរយម្ភៃ) ថ្ងៃ ស្របតាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី។

**៣-ឱ្យ**ដើមចោទឈ្មោះ [redacted] សុភា ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] សារ៉ាភាវត្តី ភេទស្រី កើតថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៤ និងឈ្មោះ [redacted] ស៊ូស៊ូ ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦។



Scanned with CamScanner

-ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងនឹងកូនបានគ្រប់ពេលវេលា ដើម្បីពិនិត្យមើលស្ថានភាពកូន ដោយភាគីដែលមានសិទ្ធិអំណាចមេបាមិនត្រូវរារាំងកូនមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយភាគីម្ខាងទៀត ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ពេលទៅសួរសុខទុក្ខកូន យោងតាមមាត្រា ១០៤០ និងមាត្រា ១០៤១ នៃក្រមរដ្ឋប្បវេណី។

**៤**-ប្រគល់ដីមួយកន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០២០២-១០៣២ លេខក្បាលដី ១០៣២ ទំហំ ៨៩៨ ម៉ែត្រការេ មានអាសយដ្ឋានស្ថិតនៅ ភូមិកន្ទ្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឲ្យដើមចោទឈ្មោះ [redacted] សុភា និងចុងចម្លើយឈ្មោះ [redacted] ចាន់រ៉ា គ្រប់គ្រង អាស្រ័យផល និងចាត់ចែង ស្មើគ្នា។

**៥**-ឱ្យចុងចម្លើយឈ្មោះ [redacted] ចាន់រ៉ា បង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូន តាមលទ្ធភាពរហូតកូនដល់នីតិភាព។

**៦**-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

**៧**-ច្រានចោលការទាមទាររបស់ដើមចោទ ផ្សេងទៀត។

-បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រម ចំពោះមុខដើមចោទ និងចុងចម្លើយ។

-ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ក្នុងរយៈពេល ០១ (មួយ) ខែ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅសៀមរាប, ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner